**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**សាលាដំបូងខេត្តកំពង់ឆ្នាំង**

សំណុំរឿងព្រហ្មទណ្ឌលេខ: ១៨៥

ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥

សំណុំរឿងជំនុំជម្រះលេខ: ១៤៤

ចុះថ្ងៃទី២២ ខែមិថុនា ឆ្នាំ២០១៦

សាលក្រមព្រហ្មទណ្ឌលេខ: **១២៤(ត)**

ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០

## តាងនាមប្រជារាស្ត្រខ្មែរ

**សាលាដំបូង ខេត្តកំពង់ឆ្នាំង**

បានបើកសវនាការជាសាធារណៈនៅសាលសវនាការ នៃសាលាដំបូង ខេត្តកំពង់ឆ្នាំង។

កាលបរិច្ឆេទបើកសវនាការ ថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ វេលាព្រឹក

កាលបរិច្ឆេទប្រកាសសាលក្រមថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ វេលាព្រឹក

**ចៅក្រមជំនុំជម្រះ**

លោក [redacted] ចៅក្រមសាលាដំបូងខេត្តកំពង់ឆ្នាំង

**តំណាងអយ្យការ**

លោក [redacted] ព្រះរាជអាជ្ញារងអមសាលាដំបូងខេត្តកំពង់ឆ្នាំង

**ក្រឡាបញ្ជីសវនាការ**

លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូងខេត្តកំពង់ឆ្នាំង

ដើម្បីជំនុំជម្រះសំណុំរឿងព្រហ្មទណ្ឌលេខ១៨៥ ចុះថ្ងៃទី២៤ ខែមីនា ឆ្នាំ២០១៥ ដែលមានជនជាប់ចោទ:

១.ឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ១៩ឆ្នាំ ជនជាតិខ្មែរ មុខរបរមិនពិតប្រាកដ មានទីកន្លែងកំណើតភូមិ [redacted] ខេត្តកំពង់ឆ្នាំង មានទីលំនៅស [redacted] ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] សុខុម (រ) ម្តាយឈ្មោះ [redacted] សុភាព (រ) នៅលីវ ទោសពីមុន គ្មាន ។ (ក្រៅឃុំ)

ជាប់ចោទពីបទ: រក្សាទុក ចែកចាយ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងចិក្សា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីខែមករា ឆ្នាំ២០១៥ ។ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ , ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

មានលោក [redacted] ជាមេធាវីការពារសិទ្ធិ

តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៥៨៧ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរនៃសាលាដំបូងខេត្តកំពង់ឆ្នាំង។

បានឃើញដីកាចាត់តាំងចៅក្រមជំនុំជម្រះលេខ៣៧៥ ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ ២០១៦ របស់ប្រធានសាលាដំបូងខេត្តកំពង់ឆ្នាំង ។

**អង្គហេតុកើតមានឡើងដូចតទៅ:**

កាលពីអំឡុងខែមករា ឆ្នាំ២០១៥ កម្លាំងអធិការដ្ឋាននគរបាលក្រុងកំពង់ឆ្នាំង បានទទួលពត៌មានពីប្រជាពលរដ្ឋ ដែលបានរាយការណ៍ថា កើតមានករណី រក្សាទុក ជួញដូរ ចែក

ចាយ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តឡើងនៅចំណុចផ្ទះឈ្មោះ [redacted] សុវណ្ណារ៉ា ហៅ ម៉ៅ ស្ថិតនៅក្នុងភូមិត្រពាំងចិក្សា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ជាមុខសញ្ញាចែកចាយគ្រឿងញៀនយ៉ាងសកម្ម ។

## នាពេលសវនាការ

១.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សើរី បានឆ្លើយថា: កាលពីឆ្នាំ២០១៥ វេលាម៉ោងប្រហែល៥ ទៅ៦ល្ងាច ខ្លួនកំពុងផឹកស្រានៅផ្ទះរបស់ឈ្មោះ [redacted] ចំរើន ក្នុងភូមិត្រពាំងចិក្សា សង្កាត់កំពង់ឆ្នាំង ជាមួយឈ្មោះ [redacted] ចំរើន និងបីនាក់ទៀតមិនស្គាល់ឈ្មោះ ពេលកំពុងផឹកនោះ ឈ្មោះ [redacted] ចិន្តា បានចូលមក ហើយខ្លួនហៅមកផឹកជាមួយ និងបាននិយាយលេងសើចសប្បាយ ពេលកំពុងផឹកនោះក៏ឈ្មោះ [redacted] ចិន្តា បាននិយាយប្រាប់ពួកខ្លួនថា ឈ្មោះ [redacted] សុវណ្ណារ៉ា បានចែកចាយគ្រឿងញៀននៅក្នុងភូមិត្រពាំងចិក្សាយ៉ាងសកម្ម ចំពោះថាមានអាវុធ(កាំភ្លើងខ្លីគ្រាប់ចំនួន០៣គ្រាប់នោះ)ខ្លួនមិនបានស្តាប់ទេ ពីព្រោះខ្លួនរវល់ជជែកជាមួយមិត្តភក្តិផ្សេងទៀត ។

២.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ចិន្តា បានឆ្លើយថា: កាលពីឆ្នាំ២០១៤ ខ្លួនបានធ្វើជាកម្លាំងបង្កប់ឲ្យប៉ូលីសឈ្មោះ វណ្ណៈ ប៉ូលីសមេប៉ុស្តិ៍ដំរីស កាលនោះខ្លួនបានជក់ថ្នាំញៀនម៉ាទឹកកកជាមួយឈ្មោះ [redacted] សុវណ្ណារ៉ា វាបានទិញយកមកជក់ វាប្រាប់ថាទិញពីព្រៃខ្មែរ វាមិនបានប្រាប់ឈ្មោះអ្នកលក់ថ្នាំទេ ។ កាលនោះឃើញឈ្មោះ [redacted] សុវណ្ណារ៉ា មានកាំភ្លើងខ្យល់បាញ់គ្រាប់កង់ ។ ខ្លួនមិនដែលឃើញវាលក់ដូរថ្នាំញៀនម៉ាទឹកកកទេ ហើយក៏មិនបានឃើញអ្នកផ្សេងមកទិញពីឈ្មោះ [redacted] សុវណ្ណារ៉ា ដែរ ។ ខ្លួនបានដឹងថាឈ្មោះ [redacted] សុវណ្ណារ៉ា ទៅមណ្ឌលកែប្រែប៉ុន្តែមិនចាំឆ្នាំ ។ ក្រោយពីឆ្នាំ២០១៤មកខ្លួនបានបែកពីឈ្មោះ [redacted] សុវណ្ណារ៉ា មិនដឹងថាវាជក់ ចែកចាយ លក់ដូរនូវថ្នាំញៀនម៉ាទឹកកក ឬយ៉ាងណាទេ ឃើញវានៅតែផ្ទះធ្វើស្រែចំការឪពុកម្តាយវា ហើយក៏មិនធ្លាប់ឮវាជក់ថ្នាំញៀន ចែកចាយ លក់ដូរថ្នាំញៀនអ្វីដែរ

៣.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ហៃ បានឆ្លើយថា: ខ្លួនជាអនុភូមិត្រពាំងចិក្សា កាលពី៣ទៅ៤ឆ្នាំមុន ខ្លួនឮគេថា ឈ្មោះ [redacted] សុវណ្ណារ៉ា បានប្រើប្រាស់គ្រឿងញៀនរហូតដល់ឪពុកម្តាយរបស់គាត់យកទៅដាក់នៅមណ្ឌលកែប្រែខេត្តបន្ទាយមានជ័យ។ ក្រោយមកទៀតនៅឆ្នាំ២០១៥ និងមកដល់បច្ចុប្បន្ននេះ មិនឮសូរប្រើប្រាស់ ឬចែកចាយ ជួញដូរគ្រឿងញៀនទេ ។ ជាក់ស្តែងឃើញគាត់ជួយធ្វើស្រែចំការឪពុកម្តាយ។ បើសិនគាត់នៅប្រើប្រាស់ ឬចែកចាយ ជួញដូរគ្រឿងញៀនច្បាស់ជាលេចឮពត៌មានមិនខាន ប៉ុន្តែសព្វថ្ងៃនេះមិនឮអ្វីទេ។

៤.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] អិល បានឆ្លើយថា: ខ្លួនជាមេភូមិត្រពាំងចិក្សា កាលពីមុនខ្លួនធ្លាប់ដឹងថាឈ្មោះ [redacted] សុវណ្ណារ៉ា ប្រើប្រាស់គ្រឿងញៀនតាមឈ្មោះ [redacted] ចិន្តា និយាយប្រាប់តែមិនចាំឆ្នាំទេ ។ ក្រោយមកទៀតនៅឆ្នាំ២០១៥ ខ្លួនឮគេថាឈ្មោះ [redacted] សុវណ្ណារ៉ា បានប្រើប្រាស់ ចែកចាយ ជួញដូរគ្រឿងញៀន តែខ្លួនមិនដែលបានឃើញផ្ទាល់ភ្នែកទេ។ បច្ចុប្បន្នឈ្មោះ [redacted] សុវណ្ណារ៉ា ខ្លួនធ្លាប់បានជួបផ្ទាល់សួរគាត់ពីបញ្ហាគ្រឿងញៀន គាត់ឆ្លើយថា គាត់ឈប់ហើយ ម្យ៉ាងទៀតបច្ចុប្បន្នខ្លួនមិនបានឮគេថាឈ្មោះ [redacted] សុវណ្ណារ៉ា ប្រើប្រាស់ ចែកចាយ ជួញដូរគ្រឿងញៀនទៀតទេគឺស្ងាត់ ។



Scanned with CamScanner

៥.លោក [redacted] ជាមេធាវីការពារសិទ្ធអោយជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: តាមកំណត់ហេតុបំភ្លឺចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរលើសាក្សីឈ្មោះ [redacted] ចំរើន និង ឈ្មោះ [redacted] សេរី បានឆ្លើយថា តាមរយៈពាក្យចចាមអារ៉ាម ដោយលឺគេនិយាយថា ឈ្មោះ [redacted] សុវណ្ណារ៉ា ជាអ្នកប្រើប្រាស់ថ្នាំញៀន និងមានអាវុធខ្លីមិនស្គាល់ម៉ាក ប៉ុន្តែអ្នកទាំងពីរមិនបានឃើញផ្ទាល់ភ្នែកទេ គ្មានភស្តុតាងជាក់លាក់ទេ និង តាមចម្លើយសាក្សីឈ្មោះ [redacted] អិល និង ឈ្មោះ [redacted] ហៃ ចាប់ពីឆ្នាំ២០១៥ មកដល់ពេលនេះមិនដែលឃើញឈ្មោះ [redacted] សុវណ្ណារ៉ា ប្រើប្រាស់គ្រឿងញៀនទេ ជាក់ស្តែងឃើញឈ្មោះ [redacted] សុវណ្ណារ៉ា ជួយធ្វើស្រែចំការជាមួយឪពុកម្តាយ។ សំណូមពរអោយតុលាការលើកលែងចោទប្រកាន់លើកូនក្តីរបស់ខ្លួនឈ្មោះ [redacted] សុវណ្ណារ៉ា ។

៦.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំ: ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី ឃើញថា ពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ហើយតាមអំណានចម្លើយរបស់សាក្សីគ្រាន់តែបានឮគេនិយាយប៉ុណ្ណោះ តំណាងអយ្យការប្តឹងសុំឲ្យលោកចៅក្រមពិនិត្យ និងសម្រេចតាមច្បាប់ ។

**ក្រោយពីបាន:**

-ស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] សេរី

-ស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ចិន្តា

-ស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] ហៃ

-ស្តាប់អំណានចម្លើយរបស់សាក្សីឈ្មោះ [redacted] អិល

-ស្តាប់អំណានឯកសារ និង កំណត់ហេតុផ្សេងៗទៀតមាននៅក្នុងសំណុំរឿង

-ស្តាប់សេចក្តីសន្និដ្ឋានប្តឹងសុំរបស់លោកតំណាងអយ្យការ

-ស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារសិទ្ធិឲ្យជនជាប់ចោទ

ក្រោយពីបានពិនិត្យភស្តុតាង និង ពិចារណាត្រឹមត្រូវតាមច្បាប់ហើយ

## សំអាងហេតុ

១. តាមដីកាបញ្ជូនសំណុំរឿងទៅជំនុំជម្រះលេខ៥៨៧ ចុះថ្ងៃទី១៤ ខែមិថុនា ឆ្នាំ២០១៦ របស់ចៅក្រមស៊ើបសួរសាលាដំបូងខេត្តកំពង់ឆ្នាំង បានសម្រេចបញ្ជូនជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា មកតុលាការដើម្បីជំនុំជម្រះពីបទ រក្សាទុក ចែកចាយ និង ប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងចិក្យា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីខែមករា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា ៤០ , ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

២.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] សេរី បានឆ្លើយថា: កាលពីឆ្នាំ២០១៥ វេលាម៉ោងប្រហែល៥ ទៅ៦ល្ងាច ខ្លួនកំពុងផឹកស្រានៅផ្ទះរបស់ឈ្មោះ [redacted] ចំរើន ក្នុងភូមិត្រពាំងចិក្យា សង្កាត់កំពង់ឆ្នាំង ជាមួយឈ្មោះ [redacted] ចំរើន និងបីនាក់ទៀតមិនស្គាល់ឈ្មោះ ពេលកំពុងផឹកនោះ ឈ្មោះ [redacted] ចិន្តា បានចូលមក ហើយខ្លួនហៅមកផឹកជាមួយ និងបាននិយាយលេងសើចសប្បាយ ពេលកំពុងផឹកនោះក៏ឈ្មោះ [redacted] ចិន្តា បាននិយាយប្រាប់ពួកខ្លួនថា ឈ្មោះ [redacted] សុវណ្ណារ៉ា បានចែកចាយគ្រឿងញៀននៅក្នុងភូមិត្រពាំងចិក្យាយ៉ាងសកម្ម ចំពោះថា

មានអាវុធ(កាំភ្លើងខ្លីគ្រាប់ចំនួន០៣គ្រាប់នោះ)ខ្លួនមិនបានស្គាល់ទេ ពីព្រោះខ្លួនរវល់ជជែកជាមួយមិត្តភក្តិផ្សេងទៀត ។

៣.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ចិន្តា បានឆ្លើយថា: កាលពីឆ្នាំ២០១៤ ខ្លួនបានធ្វើជាកម្លាំងបង្កប់ឲ្យប៉ូលីសឈ្មោះ វណ្ណ: ប៉ូលីសមេប៉ុស្តិ៍ដំរីស កាលនោះខ្លួនបានជក់ថ្នាំញៀនម៉ាទឹកកកជាមួយឈ្មោះ [redacted] សុវណ្ណារ៉ា វាបានទិញយកមកជក់ វាប្រាប់ថាទិញពីព្រៃខ្មែរ វាមិនបានប្រាប់ឈ្មោះអ្នកលក់ថ្នាំទេ ។ កាលនោះឃើញឈ្មោះ [redacted] សុវណ្ណារ៉ា មានកាំភ្លើងខ្យល់បាញ់គ្រាប់កង់ ។ ខ្លួនមិនដែលឃើញវាលក់ដូរថ្នាំញៀនម៉ាទឹកកកទេ ហើយក៏មិនបានឃើញអ្នកផ្សេងមកទិញពីឈ្មោះ [redacted] សុវណ្ណារ៉ា ដែរ ។ ខ្លួនបានដឹងថាឈ្មោះ [redacted] សុវណ្ណារ៉ា ទៅមណ្ឌលកែប្រែប៉ុន្តែមិនចាំឆ្នាំ ។ ក្រោយពីឆ្នាំ២០១៤មកខ្លួនបានបែកពីឈ្មោះ [redacted] សុវណ្ណារ៉ា មិនដឹងថាវាជក់ ចែកចាយ លក់ដូរនូវថ្នាំញៀនម៉ាទឹកកក ឬយ៉ាងណាទេ ឃើញវានៅតែផ្ទះធ្វើស្រែចំការឪពុកម្តាយវា ហើយក៏មិនធ្លាប់ឮវាជក់ថ្នាំញៀន ចែកចាយ លក់ដូរថ្នាំញៀនអ្វីដែរ

៤.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] ហៃ បានឆ្លើយថា: ខ្លួនជាអនុភូមិត្រពាំងចិក្សា កាលពី៣ទៅ៤ឆ្នាំមុន ខ្លួនឮគេថា ឈ្មោះ [redacted] សុវណ្ណារ៉ា បានប្រើប្រាស់គ្រឿងញៀនរហូតដល់ឪពុកម្តាយរបស់គាត់យកទៅដាក់នៅមណ្ឌលកែប្រែខេត្តបន្ទាយមានជ័យ។ ក្រោយមកទៀតនៅឆ្នាំ២០១៥ និងមកដល់បច្ចុប្បន្ននេះ មិនឮសូរប្រើប្រាស់ ឬចែកចាយ ជួញដូរគ្រឿងញៀនទេ ។ ជាក់ស្តែងឃើញគាត់ជួយធ្វើស្រែចំការឪពុកម្តាយ។ បើសិនគាត់នៅប្រើប្រាស់ ឬចែកចាយ ជួញដូរគ្រឿងញៀនច្បាស់ជាលេចឮពត៌មានមិនខាន ប៉ុន្តែសព្វថ្ងៃនេះមិនឮអ្វីទេ។

៥.តាមចម្លើយរបស់សាក្សីឈ្មោះ [redacted] អិល បានឆ្លើយថា: ខ្លួនជាមេភូមិត្រពាំងចិក្សា កាលពីមុនខ្លួនធ្លាប់ដឹងថាឈ្មោះ [redacted] សុវណ្ណារ៉ា ប្រើប្រាស់គ្រឿងញៀនតាមឈ្មោះ [redacted] ចិន្តា និយាយប្រាប់តែមិនចាំឆ្នាំទេ ។ ក្រោយមកទៀតនៅឆ្នាំ២០១៥ ខ្លួនឮគេថាឈ្មោះ [redacted] សុវណ្ណារ៉ា បានប្រើប្រាស់ ចែកចាយ ជួញដូរគ្រឿងញៀន តែខ្លួនមិនដែលបានឃើញផ្ទាល់ភ្នែកទេ។ បច្ចុប្បន្នឈ្មោះ [redacted] សុវណ្ណារ៉ា ខ្លួនធ្លាប់បានជួបផ្ទាល់សួរគាត់ពីបញ្ហាគ្រឿងញៀន គាត់ឆ្លើយថា គាត់ឈប់ហើយ ម្យ៉ាងទៀតបច្ចុប្បន្នខ្លួនមិនបានឮគេថាឈ្មោះ [redacted] សុវណ្ណារ៉ា ប្រើប្រាស់ ចែកចាយ ជួញដូរគ្រឿងញៀនទៀតទេតែស្ងាត់ ។

៦.ពុំមានពិរុទ្ធភាពលើជនជាប់ចោទឈ្មោះ [redacted] សុវណ្ណារ៉ា ពីបទ រក្សាទុក ចែកចាយ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងចិក្សា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីខែមករា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ , ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន ។

៧.លោក [redacted] ជាមេធាវីការពារសិទ្ធអោយជនជាប់ចោទបានធ្វើសេចក្តីសន្និដ្ឋានថា: តាមកំណត់ហេតុបំភ្លឺចុះថ្ងៃទី១៩ ខែតុលា ឆ្នាំ២០១៥ របស់ចៅក្រមស៊ើបសួរលើសាក្សីឈ្មោះ [redacted] ចំរើន និង ឈ្មោះ [redacted] សេរី បានឆ្លើយថា តាមរយ:ពាក្យចចាមអារ៉ាម ដោយលឺគេនិយាយថា ឈ្មោះ [redacted] សុវណ្ណារ៉ា ជាអ្នកប្រើប្រាស់ថ្នាំញៀន និងមានអាវុធខ្លីមិនស្គាល់ម៉ាក ប៉ុន្តែអ្នកទាំងពីរមិនបានឃើញផ្ទាល់ភ្នែកទេ គ្មានភស្តុតាងជាក់លាក់ទេ និង តាមចម្លើយសាក្សីឈ្មោះ [redacted] អិល និង ឈ្មោះ [redacted] ហៃ ចាប់ពីឆ្នាំ២០១៥ មកដល់ពេលនេះមិនដែលឃើញឈ្មោះ [redacted] សុវណ្ណារ៉ា ប្រើប្រាស់គ្រឿងញៀនទេ ជាក់ស្តែងឃើញឈ្មោះ [redacted] សុវណ្ណារ៉ា ជួយ

ធ្វើស្រែចំការជាមួយឪពុកម្តាយ។ សំណូមពរអោយតុលាការលើកលែងទោសប្រកាន់លើកូនក្តីរបស់ខ្លួនឈ្មោះ [redacted] សុវណ្ណារ៉ា ។

៨.តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានប្តឹងសុំៈ ក្រោយពីបានស្តាប់អំណានចម្លើយសាក្សី ឃើញថា ពុំមានធាតុផ្សំបទល្មើសគ្រប់គ្រាន់ ហើយតាមអំណានចម្លើយរបស់សាក្សីគ្រាន់តែបានឮគេនិយាយប៉ុណ្ណោះ តំណាងអយ្យការប្តឹងសុំឲ្យលោកចៅក្រមពិនិត្យ និងសម្រេចតាមច្បាប់ ឃើញថា មានលក្ខណៈត្រឹមត្រូវ គប្បីតុលាការពិចារណា និង សម្រេច ។

គប្បីតុលាការពិចារណា ដូចមានក្នុងសំអាងហេតុខាងលើ ។

## ហេតុដូច្នេះសម្រេច

១.ឲ្យឈ្មោះ [redacted] សុវណ្ណារ៉ា ភេទប្រុស អាយុ១៩ឆ្នាំជនជាតិខ្មែរ មានទីកន្លែងកំណើតភូមិត្រពាំងចិក្យា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង មានទីលំនៅសព្វថ្ងៃភូមិត្រពាំងចិក្យា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង ឪពុកឈ្មោះ [redacted] សុខុម (រ) ម្តាយឈ្មោះ [redacted] សុភាព (រ) នៅលីវ ទោសពីមុន គ្មាន រួចខ្លួន ពីបទៈ រក្សាទុក ចែកចាយ និងប្រើប្រាស់ដោយខុសច្បាប់នូវសារធាតុញៀន ប្រព្រឹត្តនៅភូមិត្រពាំងចិក្យា សង្កាត់កំពង់ឆ្នាំង ក្រុងកំពង់ឆ្នាំង ខេត្តកំពង់ឆ្នាំង កាលពីខែមករា ឆ្នាំ២០១៥ បទល្មើសព្រហ្មទណ្ឌមានចែងឲ្យផ្តន្ទាទោសតាមមាត្រា៤០ , ៤៥ នៃច្បាប់ស្តីពីការត្រួតពិនិត្យគ្រឿងញៀន។

២.សាលក្រមនេះជំនុំជម្រះជាសាធារណៈនៅថ្ងៃទី២៩ ខែមិថុនា ឆ្នាំ២០២០ និងប្រកាសជាសាធារណៈនៅថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ កំបាំងមុខជនជាប់ចោទ ។ ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ។

**ក្រឡាបញ្ជីសវនាការ**

ហត្ថលេខា និង ត្រា [redacted]

**ចៅក្រមជំនុំជម្រះ**

ហត្ថលេខា និង ត្រា [redacted]

---

**បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម**

**ថ្ងៃពុធ ០៣កើត ខែអាសាឍ ឆ្នាំជូត ទោស័ក.ព.ស.២៥៦៤**

កំពង់ឆ្នាំង ថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]

បានឃើញ

**ចៅក្រមជំនុំជម្រះ**

[redacted]